គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY
បំរើ ការពារ កសាង

**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ**

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍* *ថ្ងៃសុក្រ ទី០៩ ខែមករា ឆ្នាំ២០០៩* *ព្រឹត្តិប័ត្រលេខ៦៧ ឆ្នាំទី២*


| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -តុលាការកោះហៅតែពីរនាក់អ្នកភូមិលើកគ្នាមករាប់រយនាក់ | ១ |
| -ប៉ូលិសចរាចរចាប់ផ្តើមធ្វើការផាកពិន័យចំពោះអ្នកមិនពាក់មួកសុវត្ថិភាព | ៣ |
| -ស្មៀនឃុំគណបក្សកាន់អំណាចប្រើអំពើហិង្សាលើប្រជាពលរដ្ឋ | ៣ |


## តុលាការកោះហៅតែពីរនាក់ អ្នកភូមិលើកគ្នាមករាប់រយនាក់

អ្នកភូមិទូលរការពីរនាក់ ត្រូវបានតុលាការខេត្តកំពង់ឆ្នាំងកោះហៅមកសាកសួរក្នុងបទចោទប្រកាន់ថា បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ការកោះហៅរបស់តុលាការខេត្តកំពង់ឆ្នាំងនោះ ត្រូវបានអ្នកភូមិប្រមាណ ៥០នាក់នៅភូមិទូលរកា ឃុំមេលំ ស្រុកបរិបូរណ៍លើកគ្នាមកតវ៉ា ដោយខ្លាចតុលាការប្រើកិច្ចកលចាប់អ្នកភូមិដាក់ពន្ធនាគាកាលពីព្រឹកថ្ងៃទី១០ ខែធ្នូនេះ ។

បុរសអ្នកភូមិទូលរកាបានបង្ហើបប្រាប់ថា តុលាការខេត្តកំពង់ឆ្នាំងបានកោះហៅអ្នកភូមិ២នាក់ ទី ១ ឈ្មោះ **ទូន លីលា** ទី២ **ស៊ុំ សុធា** មកសាកសួរក្នុងបទចោទប្រកាន់ថា បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ។ អ្នកភូមិទូលរកាបានបន្តថាមានមនុស្ស៦នាក់បានយកដីបឹងរួមភូមិទូលរកាធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយលោក **អ៊ឹម គឹមលាង** មន្ត្រីជលផលក៏បានដកហូតដីបឹងនោះកាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០០៧ យកមកដាក់ធ្វើជាទ្រព្យសាធារណៈ ចំណែកប្រជាពលរដ្ឋក៏បានព្រមព្រៀង និងភាគីទាំង៦នាក់ក៏បានព្រមព្រៀងគ្នាហើយដែរ ។ លុះក្រោយមកជនទាំង៦នាក់នោះបានទៅកាន់កាប់ដីបឹងហើយប្រជាពលរដ្ឋមិនបានដឹងថា ជនទាំង៦នាក់កាន់កាប់ដីបឹងរដ្ឋ ហើយចេះតែទៅប្រកបរបរនេសាទលក្ខណៈគ្រួសារស្រាប់ តែក្រោយមកជនទាំង៤នាក់នេះ បានដាក់ពាក្យបណ្តឹងទៅតុលាការដោយចោទថា បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ។

អ្នកភូមិទូលរកា ដែលបានធ្វើការតវ៉ាដើម្បីឃ្លាំមើលខ្លាចក្រែងតុលាការចាប់ខ្លួនអ្នកភូមិ២នាក់ បានបន្តទៀតថាជនទាំង៦នាក់ដែលបានប្តឹងទៅតុលាការ ដើម្បីចោទប្រកាន់អ្នកភូមិទូលរកានោះមានឈ្មោះ ទី១ ឈ្មោះ **សំ សឿន** អនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ឆ្នាំង ទី២ **លឿង ធុំ** គ្រូបង្រៀននៅភូមិទូលរកា ទី៣ **ឡាយ សុខា** មេភូមិថ្មី ទី៤ **បូរ ចំរើន** ជាប្រជាពលរដ្ឋ ទី៥ **ឈយ ឈុន** ជាប្រជាពលរដ្ឋ ។ ជនទាំងអម្បាលម៉ាននេះបានរំលោភយកដីបឹងរួមភូមិទូលរកាធ្វើជាកម្មសិទ្ធិឯកជន ។ បឹងដីរដ្ឋ ដែលអ្នកភូមិរកា ឃុំមេលំ បានគ្រប់គ្រងតាំងពីឆ្នាំ១៩៨២មកម្ល៉េះហើយបឹងនេះក៏បានជួយចិញ្ចឹមប្រជាពលរដ្ឋ៩៧គ្រួសារដែលពួក គាត់ប្រកបរបរនេសាទ។

អ្នកស្រី **ស៊ុំ សុធា** ដែលមានឈ្មោះក្នុងដីការតុលាការ បានសំដែងការភិតភ័យ ខណៈពេលតុលាការបានកោះហៅអ្នកភូមិជាច្រើននាក់រួចមកហើយដើម្បីសាកសួរ ប៉ុន្តែអ្នកភូមិដែលត្រូវបានតុលាការកោះហៅសាកសួរនោះយ៉ាងហោចណាស់ក្នុង ម្នាក់បង់ ៤០០- ៥០០ដុល្លាផងដែរ ។ ស្ត្រីជនរងគ្រោះក្នុងបទចោទប្រកាន់របស់តុលាការខេត្តកំពង់ឆ្នាំងបាននិយាយថា តុលាការបានចោទ

នាងពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ប៉ុន្តែនាងអះអាងថា មិនបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ដូចការចោទប្រកាន់របស់តុលាការនោះទេ ។ នាងថាការប្រកបរបរនេសាទត្រីជាលក្ខណៈគ្រួសារជារបរធម្មតាតាំងពីបរមបុរាណទាំងភូមិ ទូលរកា ភូមិត្រពាំងអំពិល ភូមិផ្សារបរិបូរណ៍ ភូមិពន្លៃ អ្នកភូមិទាំងនោះសុទ្ធតែប្រកបរបរនេសាទដូចគ្នា ។ នាងបានបញ្ជាក់ថា ជនទាំង៦នាក់បានលួចធ្វើប្លង់កម្មសិទ្ធ លើដីបឹងរបស់រដ្ឋហើយប្រជាពលរដ្ឋមិនអាចទៅនេសាទត្រី បានទៀតទេតាំងពីជន៦នាក់បានហាមប្រាមមិនឱ្យអ្នកភូមិទៅនេសាទក្នុងអំឡុងឆ្នាំ២០០៤ ។ ទាក់ទងនឹងតុលាការចេញដីកាកោះហៅអ្នកភូមិទូលរកាជាហូរហែរមក សាកសួរ មិនមែនអ្នកភូមិ២នាក់ប៉ុណ្ណោះទេតាមពិតតុលាការបានកោះហៅអ្នកភូមិជាច្រើននាក់ ហើយចំណែកអ្នកភូមិដែលតុលាការកោះហៅមកសាកសួរនោះតំរូវឱ្យបង់លុយក្នុងម្នាក់ ៤០០-៥០០$ ។

លោក **រុន សារុំ** មន្ត្រីប្រចាំការិយាល័យតំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំងបានឱ្យដឹងថា រឿងរ៉ាវដីធ្លីនោះប្រជាពលរដ្ឋ បានប្តឹងប្តល់ទៅជនពាក់ព័ន្ធជាហូរហែរ ដោយមើលឃើញថាជនទាំង៦នាក់ ដែលដឹកនាំដោយ **សំ សឿន** អនុប្រធានមន្ទីរបរិស្ថានមិនអាចយកឈ្នះប្រជាពលរដ្ឋ បានទើបពួកគេរិះរកវិធីប្តឹងប្តល់ទៅតុលាការដើម្បីចាប់ឃុំខ្លួនទៅតុលាការ និងបំបាក់ស្មារតីប្រជាពលរដ្ឋ។ បើតាមពតិមានពីតុលាការនឹងកោះហៅប្រជាពលរដ្ឋរហូត៨០នាក់ដើម្បីសាកសួរ ហើយការកោះហៅសាកសួរប្រជាពលរដ្ឋក៏ត្រូវចំណាយលុយកាក់ផងដែរ ។ បុរសជាអ្នកដែលយកលុយពីក្រឡាបញ្ជីនៃតុលាការខេត្តកំពង់ឆ្នាំង បានមកដល់កន្លែងធ្វើការរបស់លោក ហើយលោកក៏បានចាត់តំណាងប្រជាពលរដ្ឋ និងអ្នកភូមិឱ្យចូលជួបលោក **លី កាយ** អនុប្រធានតុលាការ និង លោក **សួស សាងំ** ក្រឡាបញ្ជីដើម្បីសួរនាំឱ្យច្បាស់ថា តើការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃបំផ្លាញស្អី ពីព្រោះនៅបឹងនោះមានទឹក និងរនាមកុម្ពស្រងែតែប៉ុណ្ណោះ។

លោក **ទេន សុផល** សកម្មជនជាន់ខ្ពស់របស់គណបក្សសិទ្ធិមនុស្សបានបញ្ជាក់បន្ថែមថាទង្វើដែលជនទាំង៦នាក់ និងតុលាការធ្វើមកលើប្រជាពលរដ្ឋនៅភូមិទូលរកាមិនស្របតាមគតិយុត្តច្បាប់ទេពីព្រោះប្រជាពលរដ្ឋជាអ្នករងគ្រោះ ឯពួកអ្នកមានអំណាចចេះតែទន្ទ្រានមកលើប្រជាពលរដ្ឋ ។ លោកថាដីបឹងនោះជាបឹងសាធារណៈសំរាប់ប្រជាពលរដ្ឋរកស៊ី ប៉ុន្តែជនដែលមានអំណាចមានលុយចេះតែ ឃុបឃិតគ្នាធ្វើប្លង់បណ្ណ័កម្មសិទ្ធិធ្វើឱ្យប្រជាពលរដ្ឋស្លូតត្រង់រស់រងទុក្ខ ។

លោក **កេត សុធា** មេឃុំមេលំក្នុងស្រុកបរិបូរណ៍បានលើកឡើងថា រឿងរ៉ាវបឹងបួរនោះកើតមានតាំងពីឆ្នាំ២០០២ហើយជនទាំង៦នាក់នោះបានស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិ លើដីបឹងនោះដោយមានឯកសារគ្រប់គ្រាន់ ។ ប៉ុន្តែក្រោយមកជនទាំងនោះបានសុំច្បាប់ជីកស្រះតូចជាច្រើនទៀតនៅក្នុងផ្ទៃបឹងដើម្បីស្តុកទឹកទុកបូមដាក់ស្រែប្រាំង ។ រហូតមកដល់ពេលនេះតុលាការមិនទាន់បានចាប់ខ្លួនអ្នកភូមិនៅឡើយទេ ដោយគ្រាន់តែកោះហៅសាកសួរក្នុងបទចោទប្រកាន់បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ដោយសារអ្នកទាំង៦នាក់សំអាងទៅលើឯកសារកាន់កាប់ដើម្បីធ្វើស្រែនៅលើដីនោះ ។

លោក **សំ ច័ន្ទគា** មន្ត្រីសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៏នៅកម្ពុជាបានកត់សំគាល់ថា តុលាការចោទប្រកាន់អ្នកភូមិមិនដឹងថា តើគាត់យកចូលបានអ្វីមកធ្វើការចោទប្រកាន់អ្នកភូមិ ។ ប្រសិនបើតុលាការសំអាងថាការចោទប្រកាន់ពីបទបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ គឺមិនត្រឹមត្រូវនោះទេ ពីព្រោះបឹងនោះជាបឹងសាធារណៈ ។ លុះពេលប្រជាពលរដ្ឋទៅនេសាទត្រីបែរជាភាគីម្ខាងទៀតបិទចោទថាបំផ្លិចបំផ្លាញ ។ លោកសួរថាតើបំផ្លិចបំផ្លាញអ្វីផ្ទុយទៅវិញភាគី៦នាក់ នោះជាអ្នកខុសដែលធ្វើផ្ទុយទៅនឹងសេចក្តីសំរេច របស់សាលាខេត្តដែលបានដកដីបឹងទុកថាទ្រព្យសាធារណៈទៅហើយ ។ ម្យ៉ាងទៀតជនទាំងនោះក៏បានប្រព្រឹត្តខុសនឹងច្បាប់ផលផល ដោយសារបានជីកស្រះនៅក្នុងបឹងនោះធម្មជាតិបឹងសាធារណៈ តែមកដល់ពេលនេះតុលាការខេត្តកំពង់ឆ្នាំងបានចេញដីកាកោះប្រជាពលរដ្ឋចំនួន១៦នាក់ យោងតាមពាក្យបណ្តឹងនោះ ក៏បានចោទប្រកាន់ប្រជាពលរដ្ឋចំនួន៨០នាក់នៅក្នុងភូមិទូលរកាផងដែរ ។

## ប៉ូលីសចរាចរចាប់ផ្ដើមធ្វើការផាក ពិន័យចំពោះអ្នកមិនពាក់មួកសុវត្ថិភាព

នៅដើមខែមករា ឆ្នាំ២០០៩ ខាងមុខនេះ ប៉ូលីសចរាចរនឹងចាប់ផ្ដើមត្រួតពិនិត្យផាកពិន័យ ទៅលើអ្នកបើកបរទោចចក្រយានយន្ត ត្រីចក្រយានយន្តនៅទូទាំងប្រទេសកម្ពុជា ដែលមិនពាក់មួកការពារសុវត្ថិភាព ។ ទន្ទឹមនឹងការផាកពិន័យចំពោះអ្នកជិះម៉ូតូមិនដាក់កញ្ចក់មិនទាន់បញ្ចប់នៅឡើយ ពេលនេះប៉ូលីសចរាចរត្រូវបំពេញតួនាទីមួយទៀត គឺផាកពិនិត្យចំពោះអ្នកបើកបរទោចចក្រយានយន្ត ។

លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានអំពាវនាវកាលពីថ្ងៃទី២២ ខែធ្នូ នៅវិទ្យាស្ថានជាតិ លោក **ទិន ប្រសើរ** ប្រធានការិយាល័យចរាចរជើងគោករាជធានីមានប្រសាសន៍ថា ចាប់ពីថ្ងៃ ០១ ខែមករា ប៉ូលីសចរាចរនឹងធ្វើការផាកពិន័យ ហើយអ្នកដែលធ្វើជាគំរូគេមន្ត្រីរាជការ រហូតដល់ភូមិ-ឃុំ ហើយប្រជាពលរដ្ឋក៏ត្រូវមានកាតព្វកិច្ចដូចមន្ត្រីរាជការដែរ ។ លោកថាក្រោយពីលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ប្រកាសឱ្យប្រជាពលរដ្ឋបានពាក់មួកសុវត្ថិភាពប្រមាណ៤០-៧០% ដែលកាលមិនទាន់ប្រកាសឱ្យប្រើមានត្រឹមតែ ៤០%ប៉ុណ្ណោះ ។ នៅពេលយើងអនុវត្តច្បាប់ចរាចរនេះលោកសង្ឃឹមថា បងប្អូនប្រជាពលរដ្ឋនឹងចូលរួមអនុវត្តច្បាប់ទាំងអស់គ្នា ។ ប្រសិនបើយើងអនុវត្តពាក់មួកសុវត្ថិភាពច្រើនគ្នានឹងអាចកាត់បន្ថយគ្រោះថ្នាក់ដែលភាគច្រើននៃគ្រោះថ្នាក់ គឺប៉ះពាល់ត្រង់ក្បាល ។ លោកបន្តទៀតថាចំពោះអ្នកបើកបរទោចចក្រយានយន្ត ត្រីចក្រយានយន្តមិនពាក់មួកនឹងផាកពិន័យចំនួន ៣០០០រៀល ។ ការផាកពិន័យនេះធ្វើចំពោះតែអ្នកបើកបរប៉ុណ្ណោះមិនប៉ះពាល់ដល់អ្នកជិះខាងក្រោយនោះទេ ។ លោកក៏បានបញ្ជាក់ផងដែរថា ប្រសិនបើប៉ូលីសចរាចរប្រព្រឹត្តខុសច្បាប់ក៏ត្រូវពីព្រោះច្បាប់មិនអាចអនុញ្ញាតឱ្យប៉ូលីសប្រព្រឹត្តផ្ដេសផ្ដាសក្រៅពីការណែនាំនោះទេ ។

លោក **សុខ សាន្ត** អ្នកគ្រួងភ្នំពេញបានឱ្យដឹងថា វាជារឿងល្អហើយនៅពេលប្រជាពលរដ្ឋជិះម៉ូតូដាក់កញ្ចក់ និងពាក់មួកសុវត្ថិភាពដើម្បីការពារគ្រោះថ្នាក់ ។ ជាធម្មតាការបង្កើតច្បាប់អ្វីមួយគេត្រូវសិក្សាអំពីផលប្រយោជន៍របស់វា ថាតើប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋខ្មែរដែរឬទេ ? ជីវភាពប្រជាពលរដ្ឋសព្វថ្ងៃកំពុងតែយ៉ាប់យឺនហើយស្រាប់ និងត្រូវអនុវត្តន៏ច្បាប់នេះដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់ ។ លោកបានគូសបញ្ជាក់ទៀតថា គ្រោះថ្នាក់ចរាចរដែលកើតមានឡើងរាល់ថ្ងៃមិនមែនកើតឡើងដោយសារតែមិនដាក់កញ្ចក់ និងពាក់មួកសុវត្ថិភាពនោះទេ ។ ធាតុសំខាន់គឺការគោរពច្បាប់ចរាចរ ហើយការគោរពច្បាប់ចរាចរ ទៀតសោតលោកសង្កេតឃើញថា មន្ត្រីធំៗមួយចំនួនទៅវិញទេដែលមិនគោរពច្បាប់ចរាចរ ។

លោក **វ៉ុង ឈុន** ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យមានប្រសាសន៍ថា ចំណាត់ការរបស់ប្រមុខរាជរដ្ឋាភិបាលឱ្យពាក់មួកសុវត្ថិភាពនោះវាជាការល្អប្រសើរហើយ ដើម្បីគិតគូរអំពីសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ។ ប៉ុន្តែទន្ទឹមនឹងនោះក៏មានប៉ូលីសចរាចរមួយចំនួន តែងឆ្លៀតឱកាសដើម្បីជំរិតទាលុយពីប្រជាពលរដ្ឋដែលគាត់មិនទាន់បានអនុវត្ត ទៅតាមការណែនាំរបស់ច្បាប់ចរាចរ ។ លោកបានបន្តថា គ្រោះថ្នាកចរាចរកើនឡើងខ្ពស់អាស្រ័យដោយប្រជាពលរដ្ឋយើងមិនទាន់យល់អំពីគំនូស ឬក៏ស្លាកសញ្ញាចរាចរ និងបណ្ដាលមកពីផ្លូវតូចចង្អៀតតួយ៉ាងផ្លូវទៅកាន់បណ្ដាខេត្តនានា ។

គួរកត់សំគាល់ថាកាលពីថ្ងៃទី១៣ ខែធ្នូនេះ ប៉ូលីសចរាចរឈ្មោះ **សុខ វិសាល** បានវាយនឹងដំបងទៅលើអ្នករត់ម៉ូតូឌុបម្នាក់ឈ្មោះ **អ៊ុយ ពេញ** នៅភូមិថ្មី ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ រហូតដល់សន្លប់នៅនឹងកន្លែង ត្រង់ផ្លូវលេខ២៧១ ខណ្ឌទួលគោកជិតស្ថានស្ទឹងមានជ័យក្រុងភ្នំពេញ ដោយសារអ្នករត់ម៉ូតូឌុបរូបនេះមិនបានដាក់កញ្ចក់ម៉ូតូ និងស្លាកលេខម៉ូតូរបស់គាត់ ។

## ស្មៀនឃុំគណបក្សកាន់អំណាចប្រើ អំពើហឹង្សាលើប្រជាពលរដ្ឋ

សកម្មជន គណបក្សសិទ្ធិមនុស្សម្នាក់នៅភូមិព្រៃកកុយ ឃុំព្រៃកកុយ ស្រុកកងមាស ខេត្តកំពង់ចាម ត្រូវបានស្មៀន ឃុំព្រៃកកុយប្រើពាក្យអសុរោះ និងញូក់ញីលិខិតស្នាមខ្ចីលុយរបស់គាត់ចោលដោយសារគំនុំ ។ សកម្មជនគណបក្សសិទ្ធិមនុស្សនៅភូមិព្រៃកកុយបាននិយាយថា គាត់បានខ្ចីលុយធនាគា**អេ ស៊ី លី ដា**

ដើម្បីយកមកដោះស្រាយនូវបញ្ហាក្នុងគ្រួសាររបស់គាត់លិខិតនោះ មេភូមិបានចុះហត្ថលេខារួចហើយដែរ ។ លុះគាត់យកលិខិតនោះទៅឱ្យស្មៀនឃុំដើម្បីឱ្យមេឃុំ ហើយមេឃុំ **ហេង គី** ក៏បានស៊ីញ៉េហើយដែរ ។ ប៉ុន្តែស្មៀនឃុំឈ្មោះ **ហួត ហេងណៃ** ក៏បានឱ្យលិខិតស្នាមរបស់គាត់ទទឹក ដោយទាត់ចោលរ៉ាត់រ៉ាយ ។ គាត់នឹកឆ្ងល់ថាចុះហេតុអ្វីបានជាលិខិតរបស់អ្នកភូមិផ្សេងទៀត មិនខូចខាតហើយខូចខាតតែលិខិតស្នាមរបស់គាត់ ។ អ្នកភូមិរូបនេះបានបន្តថាទង្វើដែលស្មៀនធ្វើបែបនេះ ជាការប្រមាថមើលងាយគាត់ជាប្រជាពលរដ្ឋ និងដោយសារស្មៀនឃុំមានគំនុំរឿងដែលគាត់បានជួយអ្នកភូមិតវ៉ាករណីដែលសហគមន៍នេសាទ បានយករនាំងធ្នស់ដាក់ក្នុងព្រែកអន្លង់គគីធ្វើឱ្យស្ទះទឹកក្នុងការប្រកបរបរធ្វើស្រែប្រាំង ។ សមាគមន៏នោះក៏មានមន្ត្រីឃុំ និងស្មៀន ឃុំព្រែកកុយជាអ្នកប្ដឹងប្ដល់ប្រជាពលរដ្ឋផងដែរ ។

លោក **មៀច សាមឿន** ជំទប់ទី ១ ឃុំព្រែកកុយ មានប្រសាសន៏ថាលិខិតដាក់បញ្ចាំខ្ចីលុយធនាគារអេស៊ីលីដា លោកបានចុះហត្ថលេខារួចហើយដែរ ។ ប៉ុន្តែនៅលើកទី ១ លោកមិនទាន់បានចុះហត្ថលេខាលើលិខិតស្នាមនោះឡើយទេដោយសារ សំណុំបែបបទលិខិតនោះមិនទាន់គ្រប់ហើយមេភូមិលោកស៊ីញ៉េតែមួយច្បាប់នៅសល់មួយច្បាប់ទៀតគាត់ភ្លេចស៊ីញ៉េ ។ បើតាមទស្សនៈលោកជំទប់សូមឱ្យសាមីឯកសារនេះរៀបចំម្ដងទៀត ដើម្បីឱ្យមេភូមិស៊ីញ៉េ ។ លោកបានបន្តថា លោកបានសួរទៅស្មៀនឃុំថា ហេតុអ្វីបានជាលោកធ្វើឱ្យទទឹកនូវលិខិតស្នាម របស់គេហើយស្មៀនឃុំឆ្លើយថា លោកគ្មានចេតនាធ្វើឱ្យលិខិតនោះទទឹកទេពីព្រោះលោកយកលិខិតនោះក្នុងហោប៉ៅខោ ហើយ ប្រពន្ធរបស់ក៏បានយកទៅបោកដោយលោកមិនបានពិនិត្យពិច័្ឆយមើល ។

លោក **ហួត ហេងលាង** ស្មៀនឃុំព្រែកកុយបានឆ្លើយតបថា ឯកសារនោះលោកបានយកដាក់ក្នុងខោអាវពេលដែលប្រពន្ធរបស់លោកយកខោអាវនោះទៅត្រាំទឹកដោយមិនបាន ពិនិត្យមើល ។ ភ្ជាប់ទៅនឹងសំណួរសួរថាចុះហេតុអ្វីបានជាឯកសារទាំងនោះដាក់ក្នុងហោប៉ៅអាវទៅវិញ ហើយបែរជាមិនរៀបចំទុកដាក់នៅកន្លែងធ្វើការ ។ ស្មៀនឃុំព្រែកកុយតបថា ដោយសារ លោករវល់ជាប់ប្រជុំនៅសាលាស្រុកកងមាស ទើបយកឯកសារនោះដាក់ក្នុងហោប៉ៅ ហើយប្រពន្ធរបស់លោកក៏បានយកខោអាវ ទៅត្រាំទឹកដោយមិនពិនិត្យមើល ។

សកម្មជនថ្នាក់ខេត្តគណបក្សសិទ្ធិមនុស្ស នៅឃុំព្រែកកុយបាន និយាយថានៅពេលប្រជាពលរដ្ឋទៅពឹងពាក់ស្មៀនបង្ហាញឱ្យឥរិយាបទព្រងើយកន្តើយកាច់ ឬកកាច់រាងចំពោះប្រជាពលរដ្ឋដោយមិនចង់ធ្វើឱ្យប្រជាពលរដ្ឋ ជួនកាលស្មៀនមិនទាំងបោះត្រាឱ្យ ផងបើទោះបីជាអាជ្ញាធរឃុំស៊ីញ៉េហើយក្តីប្រជាពលរដ្ឋទៅអង្វករ ។ លោកបន្តថាជាគោលការច្បាប់ស្មៀនមិនត្រូវយកការងារបុគ្គលមកប្រើក្នុងកិច្ចការងាររដ្ឋ ហើយលោកក៏បានដកស្រង់សំដីលោកមេឃុំជាស្មៀននោះ មានចិត្តឆេវឆាវប៉ុន្តែលោកបញ្ជាក់ថាស្មៀននោះខុស ៤-៥ដងជាមួយប្រជាពលរដ្ឋ ។ លោកបានបញ្ជាក់បន្ថែមថា ស្មៀនជាអាជ្ញាកណ្ដាលហេតុអ្វីបានជាលំអៀងទៅរកគណបក្សនយោបាយតួនាទីស្មៀនបំរើប្រជាពលរដ្ឋ ចុះបើមិនបំរើប្រជាពលរដ្ឋវិញ ។


**គ្រប់គ្រងការផ្សព្វផ្សាយ**

| | | |
|---|---|---|
| **លោក** | **ម៉ឺ សាន** | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| **កញ្ញា** | **គង់ វណ្ណា** | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |

ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៩៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ


**ប៉ូលីសចរាចរនឹងចាប់ផ្ដើមធ្វើការផាកពិន័យចំពោះអ្នកមិនពាក់មួកសុវត្ថិភាព !**